# សិលាចារឹកទួលប្រាសាទក្នុង K.១៥៩៦

សិលាចារឹកខ្មែរបុរាណ បានរកឃើញជាបន្តបន្ទាប់ ក្នុងស្ថានភាពផ្សេងៗគ្នា ដែលធ្វើឱ្យបញ្ជីសារពើភណ្ឌសិលាចារឹកខ្មែរ បានកើតដល់លេខ K.១៩៦១។[១] ជាក់ស្តែង កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅ ក្រុមមន្ត្រីជំនាញនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ រួមសហការជាមួយមន្ត្រីផ្នែកសិលាចារឹកនៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា នគរបាលបេតិកភណ្ឌ នគរបាលរដ្ឋបាលឃុំទួលពង្រ ក្រុមប្រឹក្សាឃុំទួលពង្រ មេភូមិទួលប្រាសាទ បានទទួលសិលាចារឹករកឃើញថ្មីមួយផ្ទាំងពីលោក សុខ តាវ ជាប្រជាពលរដ្ឋរស់នៅភូមិទួលប្រាសាទ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ យកមករក្សាទុកនៅសារមន្ទីរខេត្តបន្ទាយមានជ័យ។ តាមរបាយការណ៍របស់សារមន្ទីរខេត្តបានបញ្ជាក់ឱ្យដឹងថា សិលាចារឹកមួយផ្ទាំងនេះ ប្រជាពលរដ្ឋខាងលើបានប្រទះឃើញនៅទួលប្រាសាទក្នុង និងបានយកមករក្សាទុកដោយដាំកប់ដីនៅខាងមុខផ្ទះ។

សិលាចារឹកមួយផ្ទាំងនេះ ចារឹកនៅលើថ្មភក់ព័ណ៌បៃតងក្រមៅ រាងបួនជ្រុងទ្រវែងជាថ្មដុល ទំនងពុំកើតឡើងពីការដាប់យកដោយមនុស្ស និងពុំបានសម្អិតសម្អាងរចនាជារូបរាងបួនជ្រុងត្រង់ស្មើ ដូចសិលាចារឹកដទៃនោះឡើយ។ អត្ថបទចារឹកនេះ ចារលើមុខទាំងបួននៃផ្ទៃថ្ម មានចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៩០៤និង៩១៤ ដែលត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៨២និង៩៩២ ស្ថិតក្នុងរាជ្យព្រះបាទជ័យវម៌្មទី៥។

ដោយសារផ្ទាំងសិលាចារឹកនេះ ពុំបានរៀបចំផ្ទៃចារឹកបានល្អ ធ្វើឱ្យយើងជួបបញ្ហាអំណានខ្វះៗ យ៉ាងនេះក្តី យើងអាចយល់សេចក្តីសិលាចារឹកនេះទាំងស្រុង។ អត្ថបទចារឹកមុខទីមួយ ចាររំលឹកកាលគ្រិស្តសករាជឆ្នាំ៩៨២ មានមនុស្សម្នាក់ដែលពុំបានបង្ហាញឈ្មោះក្នុងសិលាចារឹកនេះ បានរ៉ាប់រងរណ្តាប់បូជាដល់ប្រាសាទសិវលិង្គនៅភ្នំមួយដែលមិនបានបញ្ជាក់ឈ្មោះ។ ចំណែកឯអត្ថបទនៅមុខបីផ្សេងទៀត ជាសាច់រឿងតែមួយបន្តគ្នា ដែលចាប់ផ្តើមដោយការបង្ហាញកាលបរិច្ឆេទនៅគ្រិស្តសករាជឆ្នាំ៩៩២ ថ្ងៃសុក្រ ទី១ពេច

---

[១] យោងតាមបញ្ជីរបស់ក្រុមការងារ CIK គិតត្រឹមខែឧសភា ឆ្នាំ២០២១។ គិតមកដល់ត្រឹមខែតុលា ឆ្នាំ២០២១ នេះ ចំនួនបញ្ជីបានកើនឡើងជាបន្តទៀត។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ខែពិសាខ ជាពេលដែលដាក់ឱ្យប្រាសាទសង្គ្រោះនាពយណ៍ចូលផ្សំក្រុមជាមួយប្រាសាទនៅចន្ទ្របុរៈ។ បន្ទាប់មកជាអត្ថបទដែលបង្ហាញពីបញ្ជីគ្រឿងរណ្តាប់បូជានានា ខ្ញុំបម្រើប្រុសស្រី ដែលក្នុងនោះមាននាងជាអ្នកបម្រើម្នាក់ឈ្មោះ **កទ្រៅ** បានទិញដោយសម្លៀកចំនួន ២០ ស្រូវ២០។ បន្ទាប់មកជាបម្រាប ហាមមិនឱ្យបំផ្លាញបុណ្យរបស់គាត់(អ្នកសាងបុណ្យ) ឱ្យទទួលទោស និងឱ្យពរដល់អ្នកណាដែលមិនបានបំបាត់ធម៌(បុណ្យ)និងមានភក្តីភាព ឱ្យទទួលបានសេចក្តីសប្បាយនិងឥស្សរិយ(ក្រិទៃគ្វយ៌្យ)។ អត្ថបទសិលាចារឹកនេះ បញ្ចប់ដោយការបញ្ជាក់អំពីទ្រព្យផ្តត់ផ្គង់ដល់ស្មិង(អ្នកនៅធ្វើពិធីបូជា) បុរោហិត និងអ្នកបម្រើប្រុសស្រីរបស់ប្រាសាទ។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺខ្ញុំបម្រើស្រីទទួលបានការផ្គត់ផ្គង់តិចជាងខ្ញុំបម្រើប្រុសពាក់កណ្តាល (ប្រុសទទួលបាន១០ ស្រីទទួលបានតែ៥)។

ចំពោះសិលាចារឹករកឃើញនៅឃុំព្រៃខ្ពស់ ស្រុកបវេល ខេត្តបាត់ដំបង និងសិលាចារឹករកឃើញនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យនេះ សុទ្ធតែមានកត់ត្រារឿងធ្វើរណ្តាប់បូជាដល់ «កម្រតេងជគតចន្ទ្របុរ» ដែលបង្ហាញកាន់តែច្បាស់ថា «ចន្ទ្របុរៈ» គឺជាទឹកដីមួយផ្នែកនៃខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងត្រូវនឹងខេត្តចន្ទបុរី ប្រទេសថៃបច្ចុប្បន្ន។ គួរបញ្ជាក់ផងដែរថា កន្លងមកមានការសន្និដ្ឋានថាតំបន់ប្រាសាទស្ទឹងស្តិតនៅក្នុងទឹកដីចន្ទ្របុរៈកាលពីបុរាណនោះជាការពុំត្រឹមត្រូវទេ ផ្ទុយទៅវិញតំបន់នោះគួរតែស្ថិតនៅក្នុងដែនដីភីមបុរៈពីបុរាណ ដែលភីមបុរៈមានព្រំប្រទល់ជាប់ជាមួយចន្ទ្របុរៈ។ ម្យ៉ាងវិញទៀត ស្ថាននាម ចន្ទ្របុរៈ កាលពីបុរាណ អាចមានច្រើនទីតាំងផ្សេងគ្នា។ ប៉ុន្តែទីតាំងដែលធំនិងសំខាន់ គួរតែជាចន្ទ្របុរៈ ដែលត្រូវនឹងមួយផ្នែកនៃប្រទេសកម្ពុជា និងទីតាំងខេត្តចន្ទបុរី ប្រទេសថៃ នាពេលបច្ចុប្បន្ននេះ។

## អំណានអត្ថបទជាអក្សរខ្មែរទំនើប

### ផ្ទាំងក

១- ៩០៨គកវ្រះក

២- ម្រតេងអញគិរលិ

៣- ង្គអាយិរ្នំសំក្រាន្ត

៤- នុបញ្ចោត្សវគិ

៥- (អំ)បាលកល្បនា

៦- អញ

អត្ថបទដោយៈ ហ៊ិន ឈុនតេង

### ផ្ទាំងខ

១- ៩១៤គក្ក•(ទ)គមិ
២- រោចិវៃគាខគុក្ររា
៣- វនុនេះកម្រតេង
៤- អញ្ញិគង្គវនារាយ
៥- នត(ទ្វា[ទ]គរា)ត្រ[2]០
៦- ទៅ(សំ)គននុកម្រ
៧- តេងជគតិចន្ទ្របូវ
៨- ជ្រះសំវេយិចរុលិះម្វា
៩- យិភាវ្យតស្មិងយជ្វលិះ
១០- ម្វាយិ(វ)និលិ•យបិទ្នាលិ
១១- ម្វាយិសំលោអាជ[[អំ]]បលិ
១២- ជោ[[ង]]ខ្ញុំសិកញ្ញានិសិបំមោ
១៣- កិតែកំព្រៅតែព្ទ្និវិ
១៤- សិកញ្ញនិនុសិបំមោ
១៥- កិទក្សិនាទ្វាទគរា
១៦- ត្រ

### ផ្ទាំងគ

១- តៃកំព្រៅតិទុញ្ញិត
២- ខ្ញោញ្ញិវលតខ្ញោញ្ញិ(គ្វាង)
៣- ចាម្បនុចន្ទ្រាកិកៃ
៤- ម្វាយស្រុកៃម្វាយ
៥- ០កល្បនាអញ្ញតក
៦- ម្រតេងជគតិចន្ទ្រ
៧- បូវរង្គោជ្រះស្រុប្រ
៨- លុងលិះ៥បយ៉្យ
៩- ងមាសិ១ផ្សេះជា
១០- លិ១នៅអ្នកិតបំ
១១- បាត្តនេះធម្មអ
១២- ញ្ញិប្រេបិជ្រហ្មវិ
១៣- ម្ទិគ្វរទៃយ

### ផ្ទាំងឃ

១- ស្វយទោមជោងកំ(ប)ត
២- ជគត្តលោះ•នៅគេតវ្ទំបំ
៣- បាត្តនេះធម្មអញ្ញិនុមនិគេ
៤- ញ្យាងកក្តិយគេស្វយក្រិទៃ
៥- គ្វយ៉្យជោង០និវន្ទស្មិងអំ
៦- វេទ្យាំម្វាយិ•បុរោហិតស្រូ
៧- ច្វង្សរជេវ្យរ
៨- មិម្វាយិផ្នាំ០ទិកិសំវេយិ
៩- គ្វាលិម្វាយិ•ខ្ញុំតអ្នកិសិ
១០- ឱយិស្រុតប្បអ្នកិកន្តែ
១១- ស្រុ៥

[2] ពាក្យនេះអាចអានម្យ៉ាងទៀតថា «តតាតបាត្រ» ប៉ុន្តែជាពាក្យមានន័យពុំច្បាស់លាស់។ ដោយប្រៀបធៀបនឹងផ្ទាំងខបន្ទាត់ទី១៥-១៦ យើងយល់ថាអំណាននេះជា «ត(ទ្វា[ទ]គរា)ត្រ»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## *សេចក្ដីប្រែសម្រួលជាភាសាខ្មែរទំនើប*

### *ផ្ទាំងក*

*(១-៦) មហាសករាជឆ្នាំ៩០៤ ព្រះគម្តែងសិវលិង្គឯក្ក្មំ (សម្រាប់ពិធីបុណ្យ)សង្ក្រាន្ត និងបញ្ចោត្សវ គឺជាអម្បាលរណ្ដាប់បូជារបស់អញខ្ញុំ។*

### *ផ្ទាំងខ*

*(១-១៦) មហាសករាជឆ្នាំ៩១៤ ទី១០រោច ខែវិសាខ ថ្ងៃសុក្រ នូវព្រះគម្តែងអញ សង្ករនារាយណ៍(នាបុណ្យ)ទ្វាទសរាត្រ ទៅរួមផ្សំក្រុមជាមួយគម្តែងជគតចន្ទ្របូរ (មាន រណ្ដាប់បូជាដូចជា) ព្រះសង្វើយចរុ(ចំនួន)១លិះ ផ្ដល់ឱ្យដល់អ្នកធ្វើពិធីបូជា(/ស្មិង) (សម្រាប់)បូជា(ចំនួន)១លិះ (សម្រាប់)ពេលភ្លឺនិងយប់១ផ្ទល់ សម្ង ប្រេងគោ(ប៉ិរវាវ)ជាដើម ផង។ ខ្ញុំបម្រើ(មាន)សិកញ្ជាន សិបំមោក តៃកំប្រៀ តៃឰន្ទិវិ សិកញ្ជូន និងសិបំមោកិ ជាតង្វាយ(ទក្ខិណា សម្រាប់បុណ្យ)ទ្វាទសរាត្រ។*

### *ផ្ទាំងគនិងឃ*

*(១-៤) តៃកំប្រៀ បានទិញពីខ្លោញពល និងខ្លោញឃ្លាំងចាម្ប ដោយសម្បៀក(ចំនួន) ២០ (និង)ស្រូ(ចំនួន)២០។*

*(៥-១០) រណ្ដាប់បូជារបស់អញខ្ញុំ(ថ្វាយ)ដល់គម្តែងជគតចន្ទ្របូរ(មាន) អង្ករព្រះស្រូវ ប្រលុង(ចំនួន)៥លិះ ប្រេង(ចំនួន)១មាស ផ្សេះ(ចំនួន)១ជាល។*

*(១០-៥) នៅអ្នក(ឯណា)ដែលបំបាត់ធម៌(/បុណ្យ)អញខ្ញុំនេះ បួងសួងគប្បីព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ (និងទេព្ដា)ដទៃទៀត (ឱ្យអ្នកនោះ)សោយទោសផង កុំបី(កើតជា) មនុស្សទៀត។ នៅអ្នក(ឯណា)ដែលពុំបំបាត់ធម៌(/បុណ្យ)អញខ្ញុំនេះ និងអ្នកដែលញុំាង ភក្តី អ្នកទាំងនោះសោយនូវសេចក្ដីសប្បាយនិងឥស្សរិយ។*

*(៥-៨) គ្រឿងឧបត្ថម្ភ(ដល់)អ្នកធ្វើពិធីបូជា អំពែមួយនឹម បុរោហិតស្រូវ២ថ្លុង២កញ្ចើ ក្នុងមួយឆ្នាំ។*

*(៨-១១) ទឹកសង្វើយ១គ្វាល។ ខ្ញុំបម្រើមនុស្សប្រុសឱ្យស្រូវដប់ (មនុស្ស)ស្រី(ឱ្យស្រូវ) ប្រាំ។*

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

## វាក្យសព្ទ

សំក្រាន្ត = បុណ្យសំក្រាន្ត, បុណ្យពេលប្ដូរចក្រាសី។

បញ្ចោត្សវ = បុណ្យទាំង៥ប្រចាំឆ្នាំ។

កល្បនា = គ្រឿងវណ្ណាប់បូជា។

ទ្វាទគរាត្រ = ១- ទ្វាទសរាត្រី, រាត្រីថ្ងៃទី១២កើត/រនោច។

២- ពិធីបុណ្យសពមានរយៈពេល១២យប់។

ចរុ = ម្ហូបតង្វាយចំពោះព្រះឥសូរ។

លិះ = ខ្នាតរង្វាល់ធញ្ញជាតិ។

ភាវ្យ = ការផ្ដល់ឱ្យ។

ស្មិង = មេស្មិង, អ្នកធ្វើពិធីបូជា។

វន៑លិ = ពន្លឺ។

សំលោ = សម្ល។

ទ្នាល់ = ក្អមធ្នល់។

សិ = ឋានន្តរនាមខ្ញុំបម្រើប្រុស។

តៃ = ឋានន្តរនាមខ្ញុំបម្រើស្រី។

ទក្សិនា = ទក្ខិណា, តង្វាយដឹងគុណ។

ចន្ទ្បាក៑ = សម្លៀក។

បយ៉្យង = ប្រេង។

រង្កោ = អង្ករ។

ស្វយ = សោយ។

អំវេ = អំពែ, គោមាឧតូចៗ។

សំវេយ = សង្វោយ, គ្រឿងសោយ, សំណែន។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



មន្ត្រីជំនាញចុះទៅទទួលសិលាចារឹក (រូបថត៖ សារមន្ទីរខេត្តបន្ទាយមានជ័យ)



មន្ត្រីជំនាញចុះទៅទទួលសិលាចារឹក (រូបថត៖ សុង ឧស្សាហ៍)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



សំណៅផ្តិតសិលាចារឹកផ្ទាំងក (រូបថតៈ ហ៊ុន ឈុនតេង)



សំណៅផ្តិតសិលាចារឹកផ្ទាំងខ (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកផ្ទាំងគ (រូបថតៈ ហ៊ុន ឈុនតេង)



សំណៅផ្តិតសិលាចារឹកផ្ទាំងឃ (រូបថតៈ ហ៊ុន ឈុនតេង)